# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាចំហានទីពីរនៅព្រះសហគមន៍សន្តសិលា និងសន្តប៉ូល
# ភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២០
# ស្តាប់និងរស់នៅតាមព្រះបន្ទូល

**អត្ថបទទី១៖ កំណើតពិភពលោក ២,៧-៩.៣,១-៧ក**

ព្រះជាអម្ចាស់បានយកធូលីដីខមកសូនធ្វើជាមនុស្ស រួចព្រះអង្គផ្លុំដង្ហើមជីវិតតាមរន្ធច្រមុះគេ មនុស្សក៏មានជីវិតរស់ឡើង។ កណ ២,៧

**អត្ថបទទី២៖ រ៉ូម ៥,១២-១៩**

ដោយសារកំហុសរបស់មនុស្សតែម្នាក់ មនុស្សទាំងអស់ត្រូវជាប់ទោសយ៉ាងណា ដោយសារអំពើសុចរិតរបស់មនុស្សតែម្នាក់ មនុស្សទាំងអស់ក៏បានសុចរិត និងបានទទួលជីវិតយ៉ាងនោះដែរ។ រម ៥,១៨

**ដំណឹងល្អ៖ ម៉ាថាយ ៤,១-១១**

ព្រះយេស៊ូមានព្រះបន្ទូលទៅមារថា៖ សាតាំងអើយ! ចូរថយចេញទៅ ដ្បិតក្នុងគម្ពីរមានចែងថា *"អ្នកត្រូវថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គប៉ុណ្ណោះ"*។ មថ ៤,១០

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងមកពីគ្រប់ទីកន្លែងនៅក្នុងភូមិភាគភ្នំពេញ ថ្ងៃនេះជាថ្ងៃឱឡារិកសម្រាប់ព្រះសហគមន៍នីមួយៗភូមិភាគនីមួយៗនៅក្នុងពិភពលោកទាំងមូល។ ក្នុងភូមិភាគភ្នំពេញយើង សូមស្វាគមន៍បងប្អូន៧០នាក់ដែលសុំទទួលជីវិតថ្មីពីព្រះយេស៊ូផ្ទាល់ នៅរាត្រីបុណ្យចម្លងដែលពួកគាត់បានត្រៀមខ្លួនពីយូរឆ្នាំមកហើយ ដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូនៅក្នុងជីវិតថ្មីដែលព្រះអង្គចង់ប្រទានឲ្យ។ ពេលយើងអធិដ្ឋានយប់មិញ យើងបានស្តាប់អត្ថបទ "**មានសុភមង្គលហើយ អ្នកណាដែលព្រះជាម្ចាស់បានជ្រើសរើសធ្វើជាបុត្រធីតារបស់ព្រះអង្គ មានសុភមង្គលហើយ អ្នកណាដែលបានសម្រេចចិត្តដើរតាមមាគ៌ារបស់ព្រះជាម្ចាស់ផ្ទាល់**"។ ខ្ញុំមានសុភមង្គលដោយសារព្រះជាម្ចាស់បានជ្រើសរើសខ្ញុំ ទៅជាបុត្រធីតារបស់ព្រះអង្គ និងទីពីរខ្ញុំមានសុភមង្គលលើសពីនេះទៀត ដោយសារខ្ញុំបានសម្រេចចិត្តដើរតាមផ្លូវដែលព្រះជាម្ចាស់រៀបចំសម្រាប់ខ្ញុំ។ សម្រាប់បងប្អូនទាំង៧០នាក់ ពេលស្តាប់ព្រះបន្ទូលនេះពិតមែនមានសុភមង្គលហើយ ដោយទទួលស្គាល់ថាព្រះជាម្ចាស់បានជ្រើសរើសយើងដើម្បីធ្វើជាបុត្រាបុត្រីរបស់ព្រះអង្គ និងបានទទួលស្គាល់ថាយើងបានសម្រេចចិត្តដើរតាមព្រះយេស៊ូអស់មួយជីវិត ដោយទទួលអគ្គសញ្ញាជ្រមុជទឹកនៅរាត្រីបុណ្យចម្លងខាងមុខនេះ ណែនាំឲ្យយើងពោរពេញដោយសុភមង្គល។ នេះជាការអស្ចារ្យមួយ

ដែលជាទ្រព្យសម្បត្តិនៃជីវិតរបស់យើង ព្រះជាម្ចាស់បានបង្កើតយើងដើម្បីឲ្យយើងពោរពេញដោយសេចក្តីសុខសាន្ត និងសុភមង្គល។

អត្ថបទទីមួយ ពេលព្រះជាម្ចាស់បានបង្កើតពិភពលោក ព្រះអង្គបានបង្កើតអាដាំនិងអេវ៉ាដោយបានរៀបចំកន្លែងមួយយ៉ាងស្អាតសម្រាប់ពួកគេគឺសួនអេដេន។ ពីដើម ព្រះជាម្ចាស់បានបង្កើតមនុស្សយើងជាបុរសជាស្ត្រី និងបានដាក់យើងនៅក្នុងសួនមួយយ៉ាងស្អាតបំផុត ដើម្បីណែនាំឲ្យមនុស្សយើងពោរពេញដោយសុភមង្គលនិងសេចក្តីសុខ។ ប៉ុន្តែ ព្រះជាម្ចាស់បានបង្ហាញដើមឈើមួយនិងហាមគេកុំឲ្យហូបផ្លែវា តែមានសត្វពស់បានល្បួងឲ្យអាដាំនិងអេវ៉ាហូបផ្លែឈើនោះ។ ពីដើមព្រះជាម្ចាស់ ចង់ឲ្យមនុស្សយើងស្គាល់តែល្អ ស្គាល់តែសុភមង្គលនិងសេចក្តីសុខ ពេលយើងហូបផ្លែនោះណែនាំឲ្យយើងចូលនៅក្នុងរបៀបថ្មីនៃជីវិតរបស់យើង យើងដឹងអ្វីដែលល្អនិងយើងដឹងអ្វីដែលអាក្រក់។ ហេតុនេះហើយ ណែនាំឲ្យយើងត្រូវការសម្រេចចិត្តពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងសេរីភាពខ្ញុំ **តើខ្ញុំដើរតាមផ្លូវដែលល្អឬផ្លូវដែលខុស?** ពីដើមមានតែល្អដូច្នេះយើងគ្មានជម្រើសទេ ដោយសារព្រះជាម្ចាស់ចង់ឲ្យមនុស្សមានសុភមង្គល។ ប៉ុន្តែ ពេលមនុស្សបានហូបផ្លែឈើដែលព្រះជាម្ចាស់ហាម ណែនាំឲ្យមនុស្សយើងរស់នៅក្នុងបរិយាកាសមួយដែលយើងដឹងនេះជាអំពើល្អ នេះជាអំពើអាក្រក់ ពីមួយថ្ងៃទៅមួយថ្ងៃយើងត្រូវការជ្រើសរើសផ្លូវមួយ **តើខ្ញុំដើរតាមផ្លូវល្អឬផ្លូវអាក្រក់?** ពីពេលនេះតទៅ នៅក្នុងសេរីភាពរបស់យើងជួនកាលយើងវង្វេងផ្លូវណែនាំឲ្យយើងដើរតាមផ្លូវមិនល្អ។ យើងចង់ធ្វើអំពើល្អ ប៉ុន្តែពេលខ្លះយើងច្រឡំនិយាយដើមគេ យើងឈ្លោះជាមួយគេ យើងធ្វើបាប... ព្រះជាម្ចាស់ពីដើមព្រះអង្គមិនចង់ឲ្យមានបែបហ្នឹងទេ ព្រះជាម្ចាស់ចង់ឲ្យយើងពោរពេញដោយសេចក្តីសុខ។

ថ្ងៃនេះ បងប្អូនដែលបានទទួលការត្រាស់ហៅយ៉ាងឱឡារិក ថ្ងៃខាងមុខយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលាបថ្ងាស អគ្គសញ្ញាទទួលព្រះកាយព្រះគ្រីស្ត។ ក្នុងសេរីភាពរបស់យើង យើងបានជ្រើសរើសផ្លូវមួយដែលណែនាំឲ្យយើងទទួលសុភមង្គលពីព្រះជាម្ចាស់ផ្ទាល់ ព្រះជាម្ចាស់ចង់ឲ្យយើងរស់នៅក្នុងសេចក្តីសុខ ហើយយើងសុខចិត្តដើរតាមព្រះអង្គ។ បន្តិចទៀត យើងស្តាប់សក្ខីភាពពីបងធម៌ សក្ខីភាពពីគ្រូអប់រំជំនឿ សក្ខីភាពពីបូជាចារ្យ ទាំងបីសក្ខីភាពមានអត្ថន័យដែលណែនាំឲ្យយើងនឹកឃើញ យើងធ្វើដូចម្តេចដើម្បីរស់នៅក្នុងសេចក្តីសុខ។ សក្ខីភាពទីមួយ **តើបងប្អូនទាំងអស់នេះព្យាយាមស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ឬទេ?** បងធម៌ឆ្លើយថា **បាទ ចាស គេព្យាយាមស្តាប់ព្រះបន្ទូលព្រះជាម្ចាស់។** សក្ខីភាពទីពីរ **តើបងប្អូនទាំងនេះចាប់ផ្តើមរស់នៅស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ឬទេ?** គ្រូអប់រំជំនឿឆ្លើយថា **បាទ ចាស គេចាប់ផ្តើមរស់នៅស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតមែន។** សក្ខីភាពទីបី **តើបងប្អូនទាំង**

**នេះចាប់ផ្តើមរួមរស់ទៅជាបងប្អូន ហើយតែងចូលរួមក្នុងការអធិដ្ឋានឬទេ?** លោកបូជាចារ្យឆ្លើយថា **បាទ គេចាប់ផ្តើមរួមរស់ជាបងប្អូន និងចូលរួមអធិដ្ឋានជាមួយយើងមែន។** នេះជាផ្លូវនៃជីវិតរបស់យើងចាប់ពីពេលនេះតទៅ ទីមួយស្តាប់ព្រះបន្ទូល ទីពីររស់នៅតាមព្រះបន្ទូល ទីបីរួមរស់ជាបងប្អូននៅក្នុងព្រះសហគមន៍ និងចូលរួមការអធិដ្ឋាន។

សព្វថ្ងៃ នៅក្នុងជីវិតរបស់យើងមានការល្បួងច្រើនណាស់ ពីមួយថ្ងៃទៅមួយថ្ងៃមានសត្វពស់តូចធំដែលនិយាយល្បួងយើង។ សង្គមរបស់យើង ណែនាំឲ្យយើងដើរតាមផ្លូវផ្សេងពីការស្តាប់ព្រះបន្ទូល ផ្សេងពីការអនុវត្តព្រះបន្ទូលនៅក្នុងជីវិត ផ្សេងពីការទទួលស្គាល់បងប្អូននៅក្នុងព្រះសហគមន៍ ផ្សេងពីការជម្រុញឲ្យយើងអធិដ្ឋាន។ ព្រះយេស៊ូក៏បានទទួលការល្បួងដូចយើងបានទទួលពីមួយថ្ងៃទៅមួយថ្ងៃដែរ ការល្បួងទីមួយគឺណែនាំឲ្យព្រះយេស៊ូមើលទ្រព្យសម្បត្តិដែលមាននៅក្នុងពិភពលោក។ ល្បួងព្រះយេស៊ូ ឲ្យចង់បានទ្រព្យសម្បត្តិ មានចិត្តលោភលន់ ប៉ុន្តែព្រះយេស៊ូបានឆ្លើយតបថា "**មនុស្សមិនមែនរស់ដោយសារអាហារប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់វិញ**"។ ព្រះបន្ទូលដែលយើងបានស្តាប់ ត្រូវការដឹកនាំជីវិតរបស់យើង កុំឲ្យយើងលោភលន់ណែនាំឲ្យយើងចង់មានទ្រព្យសម្បត្តិយ៉ាងច្រើន និងព្រះបន្ទូលរបស់ព្រះជាម្ចាស់លែងមានតម្លៃនៅក្នុងជីវិតរបស់យើង។

ការល្បួងទីពីរដែលមារបានល្បួងព្រះយេស៊ូ ដើម្បីឲ្យព្រះអង្គមានអំណាចលើសគេ ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលថា "**កុំល្បួងលព្រះជាម្ចាស់ឡើយ**" មារសាតាំងចង់ឲ្យព្រះយេស៊ូបញ្ជាទៅទេវទូត បញ្ជាទៅព្រះជាម្ចាស់។ ពីសម័យដើម មនុស្សយើងចង់ធ្វើធំជាងព្រះជាម្ចាស់ ដោយបានសាងសង់កំពូលមួយយ៉ាងខ្ពស់ ដើម្បីលើសព្រះជាម្ចាស់។ កុំឲ្យយើងសាងសង់ជីវិតរបស់យើងដោយមិនត្រូវការព្រះជាម្ចាស់ យើងមានអំណាច យើងមានសមត្ថភាព យើងមិនត្រូវការទីពឹងលើព្រះជាម្ចាស់។ ពេលយើងទទួលជំហានទីមួយ យើងបានប្រកាសថាខ្ញុំសូមទីពឹងលើព្រះជាម្ចាស់ ខ្ញុំសូមទីពឹងលើព្រះសហគមន៍ ខ្ញុំសូមទីពឹងលើព្រះបន្ទូល។ យើងទីពឹងលើព្រះជាម្ចាស់ ដោយដឹងថាយើងមានចិត្តគំនិតដូចកូនក្មេងម្នាក់ដែលស្រឡាញ់ព្រះជាម្ចាស់ ទុកឲ្យព្រះជាម្ចាស់ណែនាំយើង មិនមែនណែនាំជីវិតរបស់យើងផ្ទាល់ខ្លួនដោយប្រើអំណាច។

ការល្បួងទីបី គឺមារសាតាំងណែនាំឲ្យព្រះយេស៊ូថ្វាយបង្គំ គោរពដល់ទ្រព្យសម្បត្តិនៃពិភពលោក ព្រះយេស៊ូឆ្លើយថា "**អ្នកត្រូវថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គប៉ុណ្ណោះ**" កុំឲ្យយើងច្រឡំព្រះជាម្ចាស់។ ប្រសិនបើ យើងយកលោកីយ៍ជាព្រះរបស់យើងបន្តិចម្តងៗយើងនៅឆ្ងាយពីព្រះជាម្ចាស់ នេះជាការល្បួងពីដើមរៀងមក។ នៅពេលប្រជារាស្ត្រអ៊ីស្រាអែលធ្វើដំណើរនៅក្នុងវាលរហោស្ថាន៤០ឆ្នាំ គេបានប្រមូលមាសប្រាក់ដើម្បីសូនរូបគោមួយដើម្បី

គោរព។ យើងភ្ជាប់ជាមួយព្រះជាម្ចាស់អស់មួយជីវិត ទោះបីយើងមានការល្បួងនានានៅក្នុងសង្គមកុំឲ្យយើងចាញ់ការល្បួងទាំងនោះ។

ពិតមែន ថ្ងៃនេះយើងពោរពេញដោយសេចក្តីសុខសាន្ត ដោយដឹងថា៤០ថ្ងៃទៀតយើងនឹងទទួលជីវិតថ្មីតាមរយៈអគ្គសញ្ញាជ្រមុជទឹក យើងមានក្រុមគ្រួសារមួយយ៉ាងធំដែលស្រឡាញ់យើង ដែលអធិដ្ឋានសម្រាប់យើង។ ដូច្នេះ បងប្អូនដែលជាគ្រីស្តបរិស័ទទាំងអស់យើងអធិដ្ឋានយ៉ាងជិតស្និទ្ធបំផុតជាមួយបងប្អូន៧០នាក់ ដែលត្រៀមខ្លួនទទួលជីវិតថ្មីនៅរាត្រីបុណ្យចម្លងខាងមុខ។ នៅក្នុងរដូវ៤០ថ្ងៃនេះ យើងទុកឲ្យព្រះជាម្ចាស់លើកលែងទោសឲ្យយើងនៅក្នុងអង្គព្រះគ្រីស្ត យើងយកពេលវេលា ដើម្បីអង្គុយទល់មុខគ្នាជាមួយព្រះជាម្ចាស់នៅក្នុងការអធិដ្ឋាន ដើម្បីកើតជាមនុស្សថ្មីដោយសារការសង្គ្រោះទន្ទឹងរង់ចាំយើងជាបន្ទាន់។ ពិតមែនអ្នកដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីធ្វើជាបុត្រាបុត្រីរបស់ព្រះអង្គមានសុភមង្គលហើយ ពិតមែនអ្នកដែលសុខចិត្តដើរតាមមាគ៌ារបស់ព្រះជាម្ចាស់មានសុភមង្គលហើយ។ អាម៉ែន៕